# ដល់ហើយចាញ់ = និយមតែចាញ់??

# ចាញ់មុនដល់ = ចាញ់និយម?? (លោក យឹម កិច្ចសែ)

១. លោក ចាញ់មុនដល់ ព្រោះយល់ មិនចេះ    ហើយគ្មានតិរិះ ចេះមិនសមឈ្មោះ
ចេះត្រឹមដើរអួត អោយស្លូតក្រពះ    ស្មានៗមិនច្បាស់ ម្តងរះម្តងលិច។

២. កំណាព្យកាព្យឃ្លោង យោងនឹងសំណេរ    លោក យឹម កិច្ចសែ ផ្លែផ្កា ជាល្បិច
លើកដាក់រៀបរាប់ តភ្ជាប់ពាក្យពេចន៍    ថែមល្បោយជាល្បិច ពន្លិចអោយចាញ់។

៣. អ្នកជល់ត្រូវចេះ ប្រមាណកំលាំង    កុំអួតថាខ្លាំង ហើយមានតែអញ
ប្រជាធិបតេយ្យ មិនមែនរបាំង    យកមកតតាំង អោយអស់ទឹកចិត្ត។

៤. ត្រូវចេះប្រមើល មើលសព្វទិសា    កុំធ្វើដូចស្វា លោតទាំងល្ងង់ល្ងើត
បើចាញ់ក៏ព្រោះ ដើម្បីឈ្មោះពិត    មានអ្វីត្រូវគិត ព្រមចាញ់មួយគ្រា?

៥. ទី១ ទី២ ទាំងតូច ទាំងធំ[1]    នៅមិនព្រមផ្តុំ ប្រមូលគ្នាគ្នា
មិនព្រមសំរួល តែជ្រួលដូចទា    ព្រោះចង់ធ្វើជា បាទាក្នុងហ្វូង[2]។

៦. គួរគិតប្រមើល មើលទៅសត្វស្លាប    ពេលហើរចេញចាក ទៅណាម្តងៗ
មានមេ មានកោយ ដឹកនាំក្នុងហ្វូង    មើលមិនដែលឆ្គង ដូចហ្វូងទាទេ។

៧. ខ្ញុំប្រើពាក្យផ្តាច់ គ្មានស្តេច ឯកឧត្តម    ឬក៏ឆ្គងឆ្គាំ មិនសមជាខ្មែរ???
ឬបើលុតលួន ព្រមធ្វើមុខឆ្អែ    ទើបសមជាខ្មែរ ឬក៏យ៉ាងណា???

---

[1] បោះឆ្នោតសភា ១៩៩៣, ១៩៩៨, ២០០៣ និងបោះឆ្នោតឃុំសង្កាត់ ២០០២និងថ្មីៗ ២០០៧។

[2] អ្នកចិញ្ចឹមទា មិនដែលទុកទាឈ្មោលច្រើនក្នុងក្នុងហ្វូងទេ ហើយទាឈ្មោលទាំងនោះតែងតែជល់គ្នា ដើម្បីដណ្តើមទាញី និងចង់ធ្វើជាម្ចាស់ហ្វូង។

៨. បាទ ក្នុងចិត្តខ្ញុំពិត ជាគ្មានពូជស្តេច ដែលស៊ី ជុះអាចម៍ ហើយមិនបានការ
ចេះត្រឹមអោបស្រី សប្បាយនឹងស្រា ទុកអោយខេមរា ជាតិខ្ញុំរលាយ ។

៩. ឯកឧត្តម ឧកញ្ញា ងារមកពីស្តេច ខ្ញុំមិនចាំបាច់ រណបចិត្ត-កាយ
សំពះលន់តួរ ពួកមនុស្សអប្បាយ[៣] នាំអោយតែស្តាយ និងថោកជាតិខ្មែរ ។

១០. ខ្ញុំមិនដែលពូន យកយួនជាមួប់ ដូចឃ្លាបង្គ្រប់ ជើងកាព្យលោកទេ
ខ្ញុំស្តី ខ្ញុំថា ខ្ញុំហា ខ្ញុំជេរ បើចេះឈឺដែរ កែរខ្លួនខ្លះទៅ ។

១១. ពាក្យពិតរមែង តែងតែរមាស់ ព្រោះពាក្យពិតនោះ តែងចាក់ស៊ីជ្រៅ
ធ្វើអោយចិន្តា កើតការហ្មងសៅ ព្រោះមិនធ្លាប់ត្រូវ មានគេរិះគន់ ។

១២. ធ្លាប់តែអំណរ សាទរ និងពាក្យ បញ្ជោរចាក់ក្លៀក បញ្ចើចពីមុន
ដល់ពេលឥឡូវ ត្រូវស្តីរិះគន់ ស្រាប់តែចេញគុណ[៤] ការពារពួក-ក្រុម ។

១៣. នែ លោក យឹម កិច្ចសែ សូមលោកស្តាប់ ខ្ញុំស្លាប់ក៏មិន ទៅអោនក្បាលសុំ
យកយួន ឬសៀម អោយមកត្រួតខ្ញុំ ព្រោះចង់ធ្វើធំ ឬធ្វើស្តេចដែរ ។

១៤. បើរស់ ឬស្លាប់ ខ្ញុំសូមប្រាប់លោក ខ្មែរពិតមិនថោក ដើរពាក់មុខឆ្កែ
ព្រួសអោយតែបាន តែរណបគេ ព្រោះតែជាឆ្កែ ជាប់ប្រវាក់ម្ចាស់ ។

អាមេរិក ខែសីហា ថ្ងៃទី៣ ឆ្នាំ២០០៧



**ស្នួន សេរីរដ្ឋា**

( ខាងក្រោមនេះ ជាអត្ថបទលោក យឹម កិច្ចសែ ខែមិនា ថ្ងៃទី២៨ ឆ្នាំ២០០៧ ឆ្លើយតបនិងអត្ថបទរបស់ខ្ញុំ Loss and Win ដែលផ្សព្វផ្សាយក្នុងខែ ថ្ងៃ ដូចគ្នា)

---

[៣] ក្រុមមនុស្សប្រព្រឹត្តិតែអំពើ អប្បាយមុខ ហើយមិនដែលខ្វាយខ្វល់ពីសុខទុកពលរដ្ឋ និងការបាត់បង់ប្រទេស
[៤] ចង់និយាយថា ចេញក្បាច់គុណ ដើម្បីការពារ

## អង្គរបុរី
### សម្លេងខ្មែរនៅបរទេស

# ចាញ់មុនជល់=ចាញ់និយម??

Défaitisme??

ដោយ យឹម-កិច្ចសៃ ★ ថ្ងៃទី២៨ មីនា ២០០៧

០១- សេរីរង្គាឈ្មោះល្អណាស់ «កម្ពុជា»«សែន» (១) ច្បាស់នៅក្រោមយួន
កន្ទុយសេរីរង្គាសួន លួចពួនកន្ត្រាក់ព្រលឹងខ្មែរ ។
០២- រង្គាលោកចេះដឹងរឿងយួន អង្រ្កុនអង្រ្គួនឲ្យធ្លាក់ថ្លៃ
ហ៊ុន-សែនកៅសិបរីលើសដែរ អ៊ូ ! ខ្មែរបើជឿអស់ពូជស្រូវ ។
០៣- គ្មានទេឯ.ឧ. គ្មានពាក្យស្តេច រង្គាស្តីផ្តាច់«សែន» (២) ត្រឹមត្រូវ
លោកឫទ្ធិ(រណឫទ្ធិ)មីកូ(ថូមិកូ)ដើរលក់ផ្លូវ ប្រឆាំងង៉ូវៗមេបក្សអាប (៣)
០៤- សុខា (៤) សូប៊ែរត៍ (៥) ឫទ្ធិបក្សអន់ មីកូ (៦) សស្លន់ ទឹកមាត់សាប
ទឹកមាត់សែន (៧) ប្រែស្រែក«កាបកាប» មាត់ឆ្អាប់ធ្វើមេកៅសិបឆ្នាំ !!!(sic)
០៥- មើលងាយមើលថោកខ្មែរពេកណាស់ ហាក់ដូចជាច្បាស់ខ្មែរមានកម្ម
ម្ភៃប្លាយឆ្នាំហើយខ្មែរដេកចាំ សស្រាក់សស្រាំក្រសែនក្រ ។
០៦- បក្សល្អមួយគត់«ប្រជាជន» ! បក្សផ្សេងទុរជនខ្មៅមិនស
ជាតិខ្មែរជាតិពិតពេញហៅល្អ អ្នកខ្លះបន្ទរពួនពាក់ដួន ។
០៧- បង្អាប់បង្អន់បក្សប្រឆាំង កម្លាំងអញតូចអញអែបយួន
បើពិតជាខ្មែរពេញសំនួន កុំពួនក្រោយខ្នងយួនហាណូយ ។

----------------

(១) ហ៊ុន-សែន

(២) ហ៊ុន-សែន

(៣) បក្សអាប (ព្រាយ) ៖ ពាក្យរបស់លោកសួន-សេរីរង្គាក្នុងអត្ថបទរបស់លោក «Loss and Win» ចុះថ្ងៃទី២៨មីនា០៧ ។ អត្ថបទរបស់លោកសេរីរង្គាហាក់ដូចជានាំឲ្យបក្សប្រឆាំង «ចាញ់មុនជល់», មុនបោះឆ្នោត ។ ឯណាទៅរដ្ឋប្រជាធិបតេយ្យ បើនិយាយជម្រុះចោលបក្សឯទៀតបែបនេះ ? បក្សល្អតែមួយគត់ គឺបក្សហ៊ុន-សែន, ឯបក្សឯទៀតៗជាបក្សអន់ ជាបក្ស «អាប» ! «អស្ចារ្យ» !

(៤) កឹម-សុខា

(៥) សឺន-ស៊ូប៊ែរត៍

(៦) ស៊ីសុវត្ថិ-ធម្មិកោ និង បក្សសម-រង្ស៊ី

(៧) ហ៊ុន-សែន